# ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា

## ជំពូក ១៥

# ការកាត់បន្ថយផ្ទៃដីចម្ការមីន

អគ្គលេខាធិការដ្ឋាន

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

អគារថ្មីផ្លូវលេខ ២៧៣កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១| ០២៣-៨៨១-៤៩២

អ៊ីមែល:  deth@cmaa.gov.kh

គេហទំព័រ: www.cmaa.gov.kh

**មាតិកា**

**មាតិកា**……………………………………………………………………………ក

**គោលការណ៍កាត់បន្ថយផ្ទៃដីចម្ការមីនរបស់អាជ្ញាធរមីន** ........................................ ១

**សេចក្តីផ្តើម** ........................................................................................ ១

**ការកាត់បន្ថយផ្ទៃដីចម្ការមីន**…………………………………………………………….. ៤

**១- វិសាលភាព** ........................................................................................ ៤

**២- បទដ្ឋានយោង** ........................................................................................ ៤

**៣- វាក្យស័ព្ទ និងនិយមន័យ** ........................................................................ ៤

**៤- គោលការណ៍នានានៃការកាត់បន្ថយផ្ទៃដីចម្ការមីន**........................................ ៥

**៥- ដំណើរការស្រាវជ្រាវបច្ចេកទេស** ................................................................ ៦

**៦- ការបោសសម្អាត** ........................................................................................ ៧

**៧- ភាពជឿទុកចិត្តលើផ្ទៃដីដែលបានកាត់បន្ថយ** ................................................ ៧

**៨- ការគ្រប់គ្រងគុណភាពនៃការកាត់បន្ថយផ្ទៃដី** ................................................ ៨

**៩- ហានិភ័យ និង ការទទួលខុសត្រូវ** ........................................................ ៨

**១០- ការចងក្រងឯកសារ**........................................................................................៩

**១១- សកម្មភាពក្រោយការកាត់បន្ថយផ្ទៃដី** ................................................ ១១

**១២- ភារកិច្ច និងការទទួលខុសត្រូវ** ................................................................ ១១

- ឧបសម្ព័ន្ធ ក បទដ្ឋានយោង..........................................................................១៣
- ឧបសម្ព័ន្ធ ខ តារាងបង្ហាញពីដំណាក់កាលនីមួយៗក្នុងការការកាត់បន្ថយផ្ទៃដី.....................១៤
- ឧបសម្ព័ន្ធ គ ស្តង់ដាចាត់ថ្នាក់ប្រភេទដី..........................................................១៥
- ឧបសម្ព័ន្ធ ឃ ទំរង់កាត់បន្ថយផ្ទៃដីចម្ការមីន..................................................១៦
- ឧបសម្ព័ន្ធ ង និមិត្តសញ្ញាផែនទី..................................................................២០
- ឧបសម្ព័ន្ធ ច លក្ខខណ្ឌលប់តំបន់សង្ស័យតាមការស្រាវជ្រាវមិនបច្ចេកទេស........................២១
- ឧបសម្ព័ន្ធ ឆ អនុវត្តការស្រាវជ្រាវបច្ចេកទេស..................................................២២
- ឧបសម្ព័ន្ធ ជ ការណែនាំលើការអនុវត្តការកាត់បន្ថយផ្ទៃដី.....................................២៥

# គោលការណ៍កាត់បន្ថយផ្ទៃដីចម្ការមីនរបស់អាជ្ញាធរមីន

## សេចក្តីផ្តើម

ផ្អែកតាមរបាយការណ៍ស្រាវជ្រាវកំរិត១ (ធ្វើនៅឆ្នាំ២០០២) នៅប្រទេសកម្ពុជា ផ្ទៃដីមួយភាគធំដែលធ្លាប់សង្ស័យថាមានមីន/គ្រាប់នោះ បែរជាពុំមាន ឬ លែងមានការគម្រាមបែបនេះដែលតំរូវឲ្យធ្វើការបោសសម្អាតទាំងស្រុងទៀតហើយ។ លើសពីនេះ ក្រោយពេលបញ្ចប់សង្គ្រាម ប្រជាជនកម្ពុជាបានធ្វើចំណាកស្រុកយ៉ាងច្រើន ដែលជះឥទ្ធិលដល់ការតាំងទីលំនៅ និងការប្រើប្រាស់ដីធ្លី។ បញ្ហានេះបានញាំងឲ្យមានការទន្ទ្រានយកដីធ្លី និងការកើន ឡើងនូវអ្នកចំណូលថ្មីជាលំដាប់ ជាពិសេសនៅតាមបណ្តាខេត្តភាគពាយព្យ។ នៅខែឧសភា ឆ្នាំ២០០៦ អាជ្ញាធរ មីនបានដាក់ចេញនូវគោលការណ៍កាត់បន្ថយផ្ទៃដីចំម្ការមីន (Area Reduction policy) ដើម្បីទទួលស្គាល់ដី ដែលធ្លាប់សង្ស័យថាមានមីន ហើយប្រជាជនបានប្រើប្រាស់បង្កបង្កើនផល ដោយពុំមានសក្ខីកម្មនៃគ្រោះថ្នាក់ណា មួយ ដើម្បីដាក់បញ្ចូលក្នុងប្រព័ន្ធទិន្នន័យជាតិថាជាដីដែលបានទន្ទ្រានកាន់កាប់ និងបានប្រើប្រាស់រួច (Reclaimed Land)។ ថ្វីត្បិតតែគោលការណ៍នេះជំរុញឲ្យមានការចាត់ថ្នាក់ដីឡើងវិញអោយទៅជាដីបញ្ចប់ការគម្រាម (End-State Land) ដែលមិនចាំបាច់ដាក់ធនធានសំរាប់ធ្វើការបោសសម្អាតមីនតទៅទៀត ប៉ុន្តែវាមិនមែនជាការលើក ទឹកចិត្តដល់ភាគីពាក់ព័ន្ធ(Stakeholder) ក្នុងការដែលពួកគេត្រូវតែតម្រង់ទិសដៅធនធានរបស់ខ្លួនទៅចំកន្លែង ដែល បញ្ជាក់ច្បាស់ថាមានការគម្រាម ដើម្បីអនុវត្តនូវលទ្ធភាព និងវិធីសាស្ត្រពេញលេញ ក្នុងការកាត់បន្ថយដីសង្ស័យថា មានមីនពីភាពមន្ទិលនោះឡើយ ។

ស្តង់ដានេះផ្តល់នូវការណែនាំពីគោលការណ៍កាត់បន្ថយផ្ទៃដីទាំងមូល ជំនួសអោយគោលការណ៍កាត់បន្ថយដីឆ្នាំ២០០៦។ ការកាត់បន្ថយផ្ទៃដី គឺជាដំណើរការនៃការអនុវត្តគ្រប់មធ្យោបាយដែលសមស្រប ដើម្បីបញ្ជាក់ កំណត់ និងយកចេញនូវការសង្ស័យនិងវត្តមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងៗតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាត។

ដំណើរការកាត់បន្ថយផ្ទៃដី និងសកម្មភាពពាក់ព័ន្ធនឹងដំណើរការនេះ អាចឲ្យគ្រប់ប្រតិបត្តិករបោសសម្អាតមីនទាំងអស់នៅក្នុងប្រទេសកម្ពុជា បង្កើតបាននូវបទដ្ឋានប្រតិបត្តិការ (SOP) របស់ខ្លួន។ ប្រទេសកម្ពុជាគឺជារដ្ឋសមាជិកនៃអនុសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ដែលគេរំពឹងថានឹងមានដំណើរការកាត់បន្ថយផ្ទៃដី និងវិធីសាស្ត្រពាក់ព័ន្ធពេញលេញ ដែលអាចជួយអោយប្រទេសកម្ពុជាសម្រេចកាតព្វកិច្ចរបស់ខ្លួនកាន់តែរហ័សថែមទៀត។ លើសពីនេះ អាស្រ័យដោយធនធានបោសសម្អាតមីនកាន់តែខ្សត់ខ្សោយទៅៗ គោលការណ៍កាត់បន្ថយផ្ទៃដី នឹងជួយដល់ការតម្រង់ធនធានឲ្យចំគោលដៅលើតំបន់ដែលចាំបាច់បំផុត សម្រាប់ធ្វើការបោសសម្អាតមីនដោយកំណត់បានច្បាស់លាស់នូវប្រភេទផ្ទៃដីដែលមានការគម្រាមពិតប្រាកដ។

ស្តង់ដាជំពូកនេះត្រូវបានប្រើប្រាស់ដោយផ្សារភ្ជាប់ទៅនឹងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជាជំពូក-៦ ស្តីពីតម្រូវការនានានៃការបោសសម្អាតមីន និងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជាជំពូក-៧ ស្តីពីតំរូវការនានានៃការបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម និងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជាជំពូក- ១៤ ស្តីពីការស្រាវជ្រាវទិន្នន័យមូលដ្ឋាន។

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានបោសសម្អាតមីននៅកម្ពុជា អាជ្ញាធរមីន តម្រូវឲ្យប្រើប្រាស់វិធីសាស្ត្រកាត់បន្ថយផ្ទៃដីនេះជាអតិបរិមា ។ អាជ្ញាធរមីន តម្រូវឲ្យប្រតិបត្តិករទាំងអស់ប្រើប្រាស់ឲ្យអស់

លទ្ធភាពក្នុងការអនុវត្ត វិធីសាស្ត្រ៣សំខាន់ៗ ដើម្បីកាត់បន្ថយផ្ទៃដីដែលធ្លាប់បានកត់ត្រាថាជាតំបន់សង្ស័យមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមដូចខាងក្រោម ៖

១-ការលុបចោលតំបន់សង្ស័យ(Cancellation) តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស (Non-Technical Survey): យោងតាមស្តង់ដាសកម្មភាពកម្ចាត់មីនអន្តរជាតិជំពូក ០៧.១១ ពាក្យស្រាវជ្រាវមិនបច្ចេកទេស គឺជាការប្រមូល និងវិភាគទិន្នន័យដោយមិនចាំបាច់ប្រើប្រាស់ជំនួយបច្ចេកទេស ទៅលើវត្តមានប្រភេទ បរិស្ថានជុំវិញនិងប្រភពនៃការដាក់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីកំណត់អោយបានច្បាស់នូវតំបន់ដែលមាន និងមិនមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម ព្រមទាំងគាំទ្រដល់អាទិភាពនៃការកាត់បន្ថយផ្ទៃដី និង ដំណើរការសម្រេចចិត្តផ្អែកលើភស្តុតាងដែលទទួលបាន។ គោលបំណង គឺដើម្បីបញ្ជាក់ពីសក្តីកម្មថាតំបន់នោះមានមីន ឬអត់ ហើយថាតើមានទំហំប៉ុណ្ណា។ ការស្រាវជ្រាវមិនបច្ចេកទេស នឹងលុបចោលនូវ ការស្រាវជ្រាវដែលបានធ្វើកន្លងមក ហើយក៏អាចកាត់បន្ថយផ្ទៃដីចេញពីតំបន់សង្ស័យផងដែរ។ ព័ត៌មាន ដែលបានមកពីការស្រាវជ្រាវចំការមីនមូលដ្ឋាន ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ហើយការស្រាវជ្រាវនេះ គឺ ជាផ្នែកមួយនៃដំណើរការធ្វើផែនការប្រចាំឆ្នាំដែលត្រូវត្រួតពិនិត្យ វាយតម្លៃបឋម និងធ្វើបច្ចុប្បន្នភាព ទិន្នន័យថ្នាក់ជាតិទៅតាមអភិក្រមនោះ។

លក្ខខណ្ឌដើម្បីលុបចោលតំបន់សង្ស័យមានចែងក្នុងឧបសម្ពន្ធ ច

២-ការកាត់បន្ថយផ្ទៃដីចម្ការមីន(Reduction)តាមរយៈការស្រាវជ្រាវបច្ចេកទេស (Technical Survey) គឺជាការអង្កេតលើតំបន់សង្ស័យថាមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមតាមលក្ខណៈបច្ចេកទេស និង ពិនិត្យពិច័យដោយលម្អិតតាមផែនទី ដើម្បីកំណត់តំបន់ដែលត្រូវធ្វើការបោសសម្អាតមីន និងតំបន់ដែល ត្រូវកាត់ចេញពីតំបន់សង្ស័យថាមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម ។

ឧទាហរណ៍រួមមានៈ

- ផ្ទៃដីដែលបានកត់ត្រាជាតំបន់គម្រាមកំហែងពីមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមដែលកំណត់ដោយអ្នកបោសសម្អាតមីនដោយដៃដើម្បីវាយតំលៃពីកម្រិតនៃការគម្រាមកំហែង។
- ផ្ទៃដីដែលបានកត់ត្រាជាតំបន់គម្រាមកំហែងពីមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមដែលកំណត់ដោយការប្រើប្រាស់គ្រឿងចក្រ( ដូចជា ឧបករណ៍កាប់ គាស់ កាយដី flair, tiller, roller ។ល។
- ផ្ទៃដីដែលបានកត់ត្រាជាតំបន់គម្រាមកំហែងពីមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមដែលធ្វើដោយក្រុមសត្វហឹតរកជាតិផ្ទុះ(Explosive Detection Animals)

៣- ការកាត់បន្ថយផ្ទៃដីចម្ការតាមរយៈការបោសសម្អាត (Clearance) គឺជាដំណើរការបោសសំអាត មីនលើតំបន់ដែលបានបញ្ជាក់ច្បាស់ថាមានមីន តាមជំរៅជាក់លាក់មួយ ដោយអនុលោមតាមស្តង់ដា ជំពូក-៦ ស្តីពីតម្រូវការនានានៃការបោសសម្អាតមីន និងស្តង់ដាជំពូក-៧ ស្តីពីតម្រូវការនានានៃការបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម ។

ការកាត់បន្ថយផ្ទៃដីចម្ការមីនប្រទេសកម្ពុជា ត្រូវអនុវត្តឲ្យស្របតាមដំណើរការឬសកម្មភាពនានា ដែលបានកំណត់យ៉ាងច្បាស់នៅក្នុងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា និងបទដ្ឋានប្រតិបត្តិការ ដែលបានទទួលស្គាល់ដូចខាងក្រោមៈ

១- ដំណើរការដែលមានការកត់ត្រារក្សាទុកជាឯកសារផ្លូវការជាក់លាក់មួយ សំរាប់ស៊ើបអង្កេតដោយអនុលោមតាមបទដ្ឋានប្រតិបត្តិការដែលត្រូវបានទទួលស្គាល់ទៅលើតំបន់ដែលមានបញ្ហាមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម។

២- លក្ខណៈវិនិច្ឆ័យដែលបានកំណត់ច្បាស់លាស់ ស្របតាមទិសដៅសំរាប់ធ្វើចាត់ថ្នាក់ប្រភេទដីឡើងវិញ ដែលត្រូវបានប្រើសំរាប់ប្រព័ន្ធរៀបចំផែនការ និងចាត់អាទិភាពដីសំរាប់បោសសម្អាតមីន។

៣- ដំណើការគ្រប់គ្រងគុណភាពខាងក្រៅធ្វើដោយអាជ្ញាធរមីន។

៤- ការចូលរួមដ៏សស្រាក់សស្រាំពីសហគមន៍ និងការទទួលយកនូវការធ្វើសេចក្តីសម្រេចចិត្ត។

៥- ដំណើរការប្រគល់-ទទួលដីជាផ្លូវការ មុននឹងធ្វើការកាត់បន្ថយផ្ទៃដីចំការមីន។

៦- យន្តការត្រួតពិនិត្យមួយ បន្ទាប់ពីមានការប្រគល់-ទទួលដី។

រាជរដ្ឋាភិបាលកម្ពុជាឯកភាព នឹងមិនដាក់បន្ទុកឲ្យប្រតិបត្តិករដែលទទួលអាជ្ញាប័ណ្ណពីអាជ្ញាធរមីន ទទួលខុសត្រូវលើដីដែលបានកាត់បន្ថយពីតំបន់ដែលសង្ស័យថាមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម ក៏ដូចជាមិនដាក់បន្ទុកទៅលើដំណើរការកាត់បន្ថយផ្ទៃដី ដែលបានប្រតិបត្តិការទាំងស្រុងតាមស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជាដោយប្រតិបត្តិករដែលមានអាជ្ញាប័ណ្ណ ដោយប្រើប្រាស់បទដ្ឋានប្រតិបត្តិការ (SOP) ដែលមានការទទួលស្គាល់ ព្រមទាំងបានធានាគុណភាពដោយអាជ្ញាធរមីន (ទោះបីការកាត់បន្ថយនោះ ធ្វើឡើងតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតមីនទាំងស្រុងក៏ដោយ) ។

# ការកាត់បន្ថយផ្ទៃដីចម្ការមីន

## ១- វិសាលភាព

ស្តង់ដានេះផ្តល់ការណែនាំពីដំណើរការនៃការកាត់បន្ថយផ្ទៃដី សំរាប់ការរៀបចំបទដ្ឋានប្រតិបត្តិការ (SOPs)និងកំណត់ពីការទទួលខុសត្រូវ និងកាតព្វកិច្ចរបស់ប្រតិបត្តិករ និងភ្នាក់ងារបោសសម្អាតមីនទាំងអស់ នៅប្រទេសកម្ពុជា ។

## ២- បទដ្ឋានយោង

បញ្ជីនៃបទដ្ឋានយោងនានា មានរៀបរាប់នៅក្នុងឧបសម្ពន្ធ័-ក។ បទដ្ឋានយោងទាំងនោះ ជាឯកសារ សំខាន់ដែលត្រូវបានប្រើប្រាស់សំរាប់រៀបចំផ្នែកណាមួយ ឬខ្លឹមសារទាំងមូលនៃស្តង់ដាជំពូកនេះ។

## ៣- វាក្យស័ព្ទ និងនិយមន័យ

ពាក្យថា "កាត់បន្ថយផ្ទៃដី/Land Release"(IMAS07.11) គឺសំដៅលើដំណើរការនៃការអនុវត្តគ្រប់មធ្យោបាយដែលសមស្របដើម្បីបញ្ជាក់ កំណត់ និងយកចេញនូវការសង្ស័យនិងវត្តមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងៗតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាត។

គោលបំណងនៃ "ការស្រាវជ្រាវមិនបច្ចេកទេស/Non-Technical Survey" គឺដើម្បីបញ្ជាក់ពីភស្តុតាង នៃការគម្រាមកំហែង កំណត់ប្រភេទ និងទំហំនៃការគម្រាម និងឈានទៅកំណត់បរិមាត្រនៃតំបន់សង្ស័យថាមានគ្រោះថ្នាក់នោះ ដោយមិនចាំបាច់ធ្វើការពិនិត្យដោយផ្ទាល់ទៅក្នុងចំម្ការមីន។ នេះជាដំណាក់កាលទី១ក្នុងការបង្វែរប្រភេទដីឲ្យទៅជាដីបញ្ចប់ការគម្រាម និងអាចជាប្រភេទដីដែលលុបចោលតំបន់សង្ស័យ C1 (Cancelled Land) ដោយមិនតម្រូវឲ្យមានការបោសសម្អាតទាំងស្រុងឡើយ។ លទ្ធផលនៃការស្រាវជ្រាវមិនបច្ចេកទេស គឺជាពហុកោណដែលត្រូវបានកំណត់ដោយប្រើប្រាស់ស្តង់ដានៃចំណាត់ថ្នាក់ប្រភេទដី ដូចមាននៅក្នុងឧបសម្ព័ន្ធ-២។ ការស្រាវជ្រាវមិនបច្ចេកទេសនៅប្រទេសកម្ពុជា គឺជាដំណាក់កាលមួយដែលត្រូវប្រើប្រាស់ ដើម្បីទទួលបានព័ត៌មានបច្ចុប្បន្នភាពពីស្ថានភាពនៃតំបន់ដែលមានមីនពិតប្រាកដ។ នេះគឺជាផ្នែកមួយនៃដំណើរការរៀបចំផែនការប្រចាំឆ្នាំ ហើយស្ថានភាពនៃពហុកោណនីមួយៗ ត្រូវមានការបញ្ជាក់ឲ្យបានច្បាស់ មុននឹងចាប់ផ្តើមធ្វើការស្រាវជ្រាវបច្ចេកទេស ឬធ្វើការបោសសម្អាតទាំងស្រុង ។

"ដីទន្ទ្រាន/Reclaim land" គឺជាផ្ទៃដីដែលកាលពីមុនធ្លាប់មានការសង្ស័យ ហើយត្រូវបានគេប្រើប្រាស់ធ្វើស្រែចម្ការដោយសកម្មភាពកាប់គាស់ និងភ្ជួររាស់យ៉ាងតិចបំផុត៣ដងឬច្រើនជាងនេះដោយគ្មានគ្រោះថ្នាក់ ឬដោយគ្មានភស្តុតាងណាមួយបញ្ជាក់ថាមានមីន បើមានតម្រូវការបោសសម្អាតត្រូវមានការឯកភាពពីអាជ្ញាធរមីន។ ដីទន្ទ្រាននេះ ត្រូវបានចាត់ជាដីប្រភេទ C1 នៅក្នុងស្តង់ដាចំណាត់ថ្នាក់ប្រភេទដី។

"លុបចោលតំបន់សង្ស័យ/Cancelled Land" គឺជាដីដែលពីមុនធ្លាប់មានការសង្ស័យដោយការស្រាវជ្រាវព័ត៌មានមិនត្រឹមត្រូវ ហើយក្រោយមកត្រូវបានគេស្រាវជ្រាវមិនបច្ចេកទេសមិនមានភស្តុតាងពីមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម។

"ការស្រាវជ្រាវបច្ចេកទេស/Technical Survey" ត្រូវបញ្ជាក់ពីវត្តមានគ្រាប់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម ដែលនឹងឈានទៅដល់ការកំណត់បានជាបន្ថែមពីប្រភេទដី ដោយប្រើប្រាស់ស្តង់ដាចំណាត់ថ្នាក់ដី។ ការស្រាវជ្រាវបច្ចេកទេស ត្រូវធ្វើឡើងក្រោយពីការស្រាវជ្រាវមិនបច្ចេកទេស ឬអាចជាផ្នែកមួយក្នុងដំណើរការបោសសម្អាតមីន ដើម្បីឲ្យការពង្រាយកម្លាំងបោសសម្អាតមីន អាចផ្តោតចំគោលដៅ ទៅតាមប្រភេទនៃការគម្រាម។ លទ្ធផលនៃការស្រាវជ្រាវបច្ចេកទេស អាចនឹងទទួលបានជាតំបន់ដែលមានការគម្រាមកំហែងដែលត្រូវកាត់បន្ថយ (ជាដីប្រភេទ C2) ហើយដែលពុំចាំបាច់ឲ្យមានការបោសសម្អាតទៀតឡើយ។ ការស្រាវជ្រាវបច្ចេកទេសអាចជួយផ្តល់ព័ត៌មានដល់ដំណើរការរៀបចំផែនការបោសសម្អាតមីនទាំងស្រុងឲ្យចំគោលដៅ ដែលជាកន្លែងមានតម្រូវការចាំបាច់បំផុត ហើយដែលភាគច្រើនជាតំបន់ប្រភេទ-A ដូចមានបញ្ជាក់នៅក្នុងស្តង់ដានៃចំណាត់ថ្នាក់ប្រភេទដី។

ពាក្យថា "តំបន់សង្ស័យថាមានគ្រោះថ្នាក់(SHA) គឺផ្តោតទៅលើតំបន់ដែលមានការសង្ស័យថាមាន មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម (A1-B2)។ មុនបញ្ចូលតំបន់ SHA ទៅក្នុងទិន្នន័យថ្នាក់ជាតិ ចាំបាច់ត្រូវកំណត់ ដោយប្រើប្រាស់ស្តង់ដាចំណាត់ថ្នាក់ប្រភេទដី។ គោលបំណងនៃការឲ្យមាន SHA គឺដើម្បីកំណត់និងដាក់ផ្លាក សញ្ញាឲ្យបានច្បាស់ ដើម្បីឲ្យអ្នកប្រើប្រាស់ដីនៅក្បែរនោះស្គាល់ពីតំបន់ដែលមានគ្រោះថ្នាក់នោះ។ ការកំណត់ និយមន័យ SHA ក៏ជួយផងដែរក្នុងការស្វែងរកមធ្យោបាយសមស្រប ដើម្បីឈានទៅដល់ការផ្ទេរដីប្រភេទនេះ ទៅជាប្រភេទផ្ទៃដីបញ្ចប់ការគម្រាម។

"ការបោសសម្អាត/Clearance" ត្រូវអនុវត្តដោយអនុលោមតាមស្តង់ដាជំពូក-៦។ ការបោសសម្អាតមីនទាំងស្រុង នឹងត្រូវចាប់ផ្តើមល្គឹកណាវិធីសាស្ត្រនានានៃការស្រាវជ្រាវត្រូវបានអនុវត្ត ឬមិនអាចធ្វើការកាត់បន្ថយផ្ទៃដីតទៅទៀតបាន ដោយមានព័ត៌មានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតំបន់គ្រោះថ្នាក់នោះ ដូចមានចែងនៅក្នុងស្តង់ដានៃ ចំណាត់ថ្នាក់ប្រភេទដី។ ពេលនោះ ការបោសសម្អាតមីនទាំងស្រុងអាចប្រព្រឹត្តទៅបានតែក្នុងតំបន់ដី ប្រភេទ-A ប៉ុណ្ណោះ។

ពាក្យថា "ការស្រាវជ្រាវទិន្នន័យមូលដ្ឋាន/Baseline Survey" គឺមានចែងលម្អិតនៅក្នុងស្តង់ដាជំពូក-១៤។ ការស្រាវជ្រាវនេះ ជាវិធីសាស្ត្រនៃការស្រាវជ្រាវមិនបច្ចេកទេសដែលប្រើនៅកម្ពុជា។

ពាក្យថា "MAPU" គឺផ្តោតទៅលើអង្គភាពធ្វើផែនការសកម្មភាពកម្ចាត់មីន ដែលបានបង្កើតឡើងនៅ ថ្នាក់ខេត្ត ដើម្បីសម្របសម្រួលដំណើរការរៀបចំផែនការបោសសម្អាតមីន នៅបណ្តាខេត្តមានផលប៉ះពាល់ដោយ សារមីនខ្លាំង។ អង្គភាពនេះត្រូវមានចំណេះដឹងពីស្តង់ដានៃចំណាត់ថ្នាក់ប្រភេទដី និងធ្វើការតាមដានជាប់ជាប្រចាំ នូវការពិនិត្យដីដែលបានកាត់បន្ថយរួច ដើម្បីធ្វើបច្ចុប្បន្នភាពផែនការ និងការតម្រង់ទិសកម្លាំងបោសសម្អាតមីន ឲ្យចំគោលដៅល្អ និងមានប្រសិទ្ធភាពខ្ពស់។

## ៤- គោលការណ៍នានានៃការកាត់បន្ថយផ្ទៃដីចម្ការមីន

ដំណើរការនៃការកាត់បន្ថយផ្ទៃដីចម្ការមីន គឺជាភស្តុតាងដែលផ្អែកលើដំណើរការនៃការវាយតំលៃព័ត៌មាន ដែលអាចជួយដល់ការកំណត់ពីតំបន់ដែលត្រូវនិងមិនត្រូវបោសសម្អាតមីន។ គោលការណ៍នៃការកាត់បន្ថយផ្ទៃដីនៅកម្ពុជាមានដូចតទៅ៖

**ក-ចំណាត់ថ្នាក់ដី ៖** ស្តង់ដានៃចំណាត់ថ្នាក់ដីមានចែងនៅក្នុងឧបសម្ព័ន្ធ-គ។ ពហុកោណនៃតំបន់សង្ស័យណាមួយដែលត្រូវបានកត់បញ្ចូលទៅក្នុងទិន្នន័យថ្នាក់ជាតិ ត្រូវកំណត់ដោយការប្រើប្រាស់ស្តង់ដានៃការ

ចាត់ថ្នាក់ដីនេះ។ ដំណើរការនៃការចាត់ថ្នាក់ពហុកោណមួយ ត្រូវអនុវត្តតាមគោលការណ៍ណែនាំ ដូចមាន ចែងនៅក្នុងស្តង់ដាជំពូក-១៤ ស្តីពីការស្រាវជ្រាវទិន្នន័យមូលដ្ឋាន។ ចំពោះពហុកោណណា ដែលគ្មាន ភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីប្រភេទនៃចំណាត់ថ្នាក់ដី និងមិនមានកូអរដោនេ/និយាមកាមនៃបរិមាត្រច្បាស់លាស់ទេនោះ ពុំត្រូវបញ្ចូលទៅក្នុងទិន្នន័យជាដាច់ខាត។

ខ-ចំពោះការស្រាវជ្រាវមិនបច្ចេកទេសត្រូវអនុវត្តតាមគោលការណ៍ណែនាំដូចមានចែងនៅក្នុងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា ជំពូក-១៤។

គ- ការបោសសម្អាតមីនទាំងស្រុង ត្រូវធ្វើឡើងនៅពេលដែលវិធីសាស្ត្រនានានៃការស្រាវជ្រាវ ត្រូវបាន អនុវត្តរួចរាល់ ហើយពហុកោណដែលបានបង្រួមឲ្យមានទំហំតូចបំផុតត្រូវបានបង្កើតឡើង។ បន្ទាប់ពី បញ្ចប់ការស្រាវជ្រាវមិនបច្ចេកទេស មានពហុកោណមួយចំនួនអាចធ្វើការបោសសម្អាតមីនទាំងស្រុងបាន ដោយមិនចាំបាច់ធ្វើការស្រាវជ្រាវបច្ចេកទេស ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ-ខ ឡើយ។

ឃ-ការកាត់បន្ថយផ្ទៃដីសង្ស័យ អាចធ្វើទៅបានលុះត្រាតែមានការឯកភាពពីអ្នកផ្តល់ព័ត៌មានយ៉ាងហោចណាស់ចំនួន២នាក់ តាមការចាត់ថ្នាក់ដី និងបំពេញបានត្រឹមត្រូវនូវទម្រង់រាយការណ៍នៃការកាត់បន្ថយ ផ្ទៃដី។ ចំណុចនេះ អាចចាត់ទុកជាភស្តុតាងសមស្របដែលរាជរដ្ឋាភិបាលអាចទទួលស្គាល់ថាដីនោះ ត្រូវ បាន កាត់បន្ថយ និងមានសុវត្ថិភាពសំរាប់ការប្រើប្រាស់។

អ្នកផ្តល់ព័ត៌មាន ឬប្រភពព័ត៌មាន រួមមានៈ

- ប្រធានភូមិ/ឃុំ និង អនុប្រធាន
- អតីតទាហាន ឬ យោធិន ដែលធ្លាប់ពាក់ព័ន្ធក្នុងការដាក់មីន
- អ្នកភូមិដែលរងរបួសនៅក្នុងតំបន់សង្ស័យ
- អ្នកភូមិដែលមានសមាជិក ឬសត្វពាហនៈ បានស្លាប់នៅក្នុងតំបន់សង្ស័យ
- រូបថតដែលបានមកពីអាកាស
- មន្ត្រីបរិស្ថានមូលដ្ឋាន
- អ្នកស្រុកដែលធ្លាប់ចេញ ចូល ឬ ទៅជិតតំបន់មានមីន

## ៥- ដំណើរការស្រាវជ្រាវបច្ចេកទេស

ការស្រាវជ្រាវបច្ចេកទេសត្រូវធ្វើនៅលើតំបន់ដែលសង្ស័យថាមានគ្រោះថ្នាក់ (តំបន់ A1-B2) បន្ទាប់ពី លទ្ធផលនៃការស្រាវជ្រាវមិនបច្ចេកទេស កំណត់ថាជាដីតំបន់ប្រភេទ A ឬ B។ ត្រូវប្រើធនធានស្រាវជ្រាវ បច្ចេកទេសទៅលើតំបន់ A ដើម្បីឈានទៅបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀតពីកម្រិតគ្រោះថ្នាក់។ ការពុះមុខចូល ចម្ការមីនតាមរយៈដំណើរការនៃការស្រាវជ្រាវបច្ចេកទេស និងការប្រើប្រាស់មធ្យោបាយទាំងឡាយ ត្រូវអនុលោម ទាំងស្រុងតាមបទដ្ឋានប្រតិបត្តិការ។ ការពុះមុខចូលចម្ការមីន មិនត្រូវធ្វើលើសពី២៥ម៉ែត្រទេ ពីមុខមួយទៅមុខមួយ ប៉ុន្តែអាចបន្ថយបានដើម្បីស្វែងរកវត្ថុមានមីនអោយកាន់តែមានប្រសិទ្ធភាព។ ការប្រើបច្ចេកទេសកាត់បន្ថយផ្ទៃដី ត្រូវអនុលោមតាមគោលការណ៍ឆ្ពោះទៅទីតាំងដែលកំណត់ថាមានមីន បន្ទាប់មកពុះមុខចូលទៅក្នុងចម្ការមីន រួច ចាប់

ផ្តើមបោសសម្អាត រហូតទៅដល់ចំណុចបញ្ចប់ការគម្រាម។ ជាគោលការណ៍ ចំណុចបញ្ចប់ការគម្រាមត្រូវមាន ចំងាយ២៥ម៉ែត្រពីគ្រាប់មីនដែលរកឃើញចុងក្រោយ ប៉ុន្តែវាក៏អាចប្រែប្រួលផងដែរ អាស្រ័យលើស្ថានភាពចម្ការ មីននីមួយៗ ។

គោលការណ៍ណែនាំពីការស្រាវជ្រាវបច្ចេកទេសមានក្នុងឧបសម្ព័ន្ធ-ឆ

## ៦- ការបោសសម្អាត

លក្ខខណ្ឌនានា សម្រាប់ការបោសសម្អាតមីន មានចែងនៅក្នុងស្តង់ដាសកម្មភាពកម្ចាត់មីនជំពូក-០៦ និង ជំពូក-០៧ ។ ការប្រើប្រាស់សម្ភារៈបោសសម្អាតមីនសម្រាប់ការងារបោសសម្អាតមីន គឺមានតម្លៃខ្ពស់ ដែលទាម ទារឲ្យមានការត្រួតពិនិត្យពីប្រសិទ្ធភាពនៃការប្រើប្រាស់។ ការបោសសម្អាត គឺជាផ្នែកមួយនៃដំណើរការកាត់បន្ថយ ផ្ទៃដីចម្ការមីន ដែលត្រូវអនុវត្តតាមលំដាប់ដូចខាងក្រោម ៖

ក-ការស្រាវជ្រាវទិន្នន័យមូលដ្ឋាន បានផ្តល់ចំណាត់ថ្នាក់ប្រភេទដី ទៅតាមស្តង់ដាចំណាត់ថ្នាក់ប្រភេទដី ហើយតំបន់គ្រោះថ្នាក់ នឹងត្រូវរំលេចនៅក្នុងផែនការការងាររបស់ក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត (MAPU)។

ខ-ការស្រាវជ្រាវបច្ចេកទេសត្រូវបានប្រើប្រាស់ដើម្បីកំណត់លើពហុកោណ ដែលមានស្រាប់ឲ្យកាន់តែច្បាស់ថែមទៀត ដូចមានចែងក្នុងស្តង់ដាចំណាត់ថ្នាក់ប្រភេទដី។ ពហុកោណនីមួយៗ នឹងត្រូវពិនិត្យឡើងវិញដោយក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត(MAPU) ព្រមទាំងធ្វើការវាយតម្លៃ ដើម្បីបញ្ជាក់ថាពហុកោណនោះនៅតែមានអាទិភាព ហើយផែនការការងាររបស់ក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត (MAPU) ក៏ត្រូវធ្វើបច្ចុប្បន្នភាពឲ្យបានត្រឹមត្រូវផងដែរ។

គ-នៅពេលខ្លះ ការបោសសម្អាតមីនអាចធ្វើឡើងភ្លាម នៅពេលកំណត់ពហុកោណបានជាក់លាក់ (ដូចជាតំបន់ចម្ការមីន ក៥) ឬពហុកោណដែលមានទំហំតូច ដែលពុំចាំបាច់ធ្វើការស្រាវជ្រាវបច្ចេកទេស។

ប្រសិនបើក្នុងពេលប្រើសម្ភារៈសម្រាប់បោសសម្អាតមីន តាមការបោសសម្អាតមិនអាចរកឃើញមីន ត្រូវធ្វើការពិនិត្យឡើងវិញនូវវិធីសាស្ត្រដែលបានប្រើ ហើយត្រូវធ្វើការស្រាវជ្រាវបច្ចេកទេសទៅលើពហុកោណនោះបន្ថែមទៀតដើម្បីកំណត់តំបន់គ្រោះថ្នាក់ ឬធ្វើការកាត់បន្ថយផ្ទៃដីតំបន់នោះតាមលក្ខណៈសមស្រប។

## ៧- ភាពជឿទុកចិត្តលើផ្ទៃដីដែលបានកាត់បន្ថយ

មុនពេលកាត់បន្ថយផ្ទៃដីចេញពីតំបន់សង្ស័យ ត្រូវធានាប្រកបដោយភាពជឿទុកចិត្តខ្ពស់គ្រប់គ្រាន់ថាលែងមានសក្ខីកម្មណាមួយដែលបង្ហាញថាតំបន់នោះនៅមានការគម្រាមដោយគ្រឿងផ្ទុះតទៅទៀត។ ភាពជឿទុកចិត្តនេះអាចបញ្ជាក់បាននៅពេលដែលសហគមន៍អ្នកប្រើប្រាស់អះអាងពីទំនុកចិត្តក្នុងការប្រើប្រាស់ដី ហើយទម្រង់ទី៣ត្រូវបានបំពេញ។ សហគមន៍នឹងមានទំនុកចិត្តនៅពេលដែលពួកគេជឿថា នឹងលែងប្រទះឃើញមានមីន និងពុំមានជនរងគ្រោះដោយសារមីនតទៅទៀត។ ដើម្បីទទួលបាននូវទំនុកចិត្តនេះ ប្រតិបត្តិករត្រូវអនុវត្តដំណើរការនៃការកាត់បន្ថយផ្ទៃដី ដោយធានាឲ្យមានការចូលរួមយ៉ាងពេញលេញពីសហគមន៍ និងអ្នកទទួលផល ព្រមទាំងភាគីពាក់ព័ន្ធនឹងបញ្ហាមីនដ៏ទៃទៀតនៅក្នុងសហគមន៍។ ការចូលរួមពីសហគមន៍នេះ គឺមានសារៈសំខាន់ណាស់នៅពេលដែលការស្រាវជ្រាវបច្ចេកទេស (ធ្វើឡើងតាមលទ្ធផលនៃការស្រាវជ្រាវ) បានរកឃើញនូវភស្តុតាងគ្រាប់សល់ពីសង្គ្រាម

ដែលបង្ហាញអោយឃើញថា តំបន់សង្ស័យថាមានការគម្រាមមិនមាននៅសល់ទៀតទេនៅក្នុងសហគមន៍ នៅតែមានការភ័យខ្លាច និងនៅតែមិនព្រមប្រើប្រាស់ដី។ ស្ថានភាពបែបនេះអាចនឹងកើតមាន ទៅលើដីដែលបានចាត់ថ្នាក់ជាប្រភេទដី B2 ឬ C2។

តាមវិធីមួយករណីម្តងៗ បើសហគមន៍អ្នកប្រើប្រាស់នៅមានការភ័យខ្លាចលើតំបន់ណាមួយ ហើយទម្រង់លេខ៣ មិនទាន់អាចបំពេញបានទេនោះ អាជ្ញាធរមីនរក្សាសិទ្ធិក្នុងការពិគ្រោះបន្ថែមជាមួយសហគមន៍ និង ប្រតិបត្តិករសាម៉ី ហើយអាចស្នើសុំឲ្យប្រតិបត្តិករនោះអនុវត្តវិធានការណ៍ខ្លះៗបន្តទៀត ដើម្បីជានាឲ្យបាននូវភាព ជឿទុកចិត្តបន្ថែម។ នៅក្នុងពេលជាមួយគ្នានោះដែរ ប្រសិនបើប្រតិបត្តិករប្រាកដថាបានធ្វើតាមដំណាក់កាល សមហេតុផលអាចយកជាការបាន តែសហគមន៍នៅតែបដិសេធមិនចុះហត្ថលេខាទៅលើទម្រង់លេខ ៣ ទេនោះ ប្រតិបត្តិករអាចស្នើសុំអាជ្ញាធរមីនឲ្យអន្តរាគមន៍ ដើម្បីឈានទៅរកចំណុចព្រមព្រៀងរួមមួយ គឺត្រូវកាត់ផ្ទៃដីចម្ការ មីននោះ បន្ទាប់មកធ្វើបច្ចុប្បន្នភាពទិន្នន័យ។

## ៨- ការគ្រប់គ្រងគុណភាពនៃការកាត់បន្ថយផ្ទៃដី

ការកាត់បន្ថយផ្ទៃដីចម្ការមីន តាមរយៈការលុបចោល/Cancellation ការកាត់បន្ថយ/Reduction និងការបោសសម្អាត/Clearanceនឹងត្រូវឆ្លងកាត់ការត្រួតពិនិត្យគុណភាពដូចមានចែងនៅក្នុងស្តង់ដាសកម្មភាពកម្ចាត់មីន ជំពូក-២ និងជំពូក-៣។ ផ្ទៃដីដែលបានកាត់បន្ថយទៅជាតំបន់ C2 ត្រូវធ្វើការត្រួតពិនិត្យពីសុវត្ថិភាពដី ដោយ អាជ្ញាធរមីន មុននឹងផ្ទេរ-ប្រគល់ទៅឲ្យសហគមន៍។ ប្រតិបត្តិករត្រូវជូនដំណឹងទៅក្រុមផែនការសកម្មភាពកម្ចាត់មីន ខេត្ត (MAPU) ពីស្ថានភាពដីប្រភេទ C2 ហើយក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត(MAPU) ត្រូវជូនដំណឹង ទៅអាជ្ញាធរមីនដើម្បីធ្វើការពិនិត្យគុណភាព (QC check) ហើយត្រូវបំពេញទម្រង់កាត់បន្ថយផ្ទៃដី នៅពេលធ្វើ ការពិនិត្យគុណភាព។

## ៩- ហានិភ័យ និង ការទទួលខុសត្រូវ

បញ្ហាចម្បងដែលអាចមាន គឺការកាត់បន្ថយផ្ទៃដីចម្ការមីនតាមរយៈការលុបចោលតំបន់សង្ស័យ /Cancellation និងការកាត់បន្ថយផ្ទៃដី/Reduction នាំមកនូវហានិភ័យខ្ពស់ជាងតំបន់ដែលបានបោសសម្អាតទាំងស្រុង។ នៅប្រទេសកម្ពុជា ការទទួលខុសត្រូវ គឺផ្សារភ្ជាប់ជាមួយការមិនអនុលោមតាមគោលការណ៍ ឬនីតិវិធីដែលបានឯកភាពគ្នា។ ប្រសិនបើដំណើរការនៃការកាត់បន្ថយផ្ទៃដីបានធ្វើឡើង ដោយអនុលោមទៅតាមគោលការណ៍របស់អាជ្ញាធរមីន ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា និងបទដ្ឋានប្រតិបត្តិការរបស់ប្រតិបត្តិករនោះនឹងមិនមានអ្វីដែលប្រតិបត្តិករត្រូវទទួលខុសត្រូវឡើយ។ ប្រសិនបើប្រតិបត្តិករណាមួយត្រូវបានគេរកឃើញថា មិនអនុលោមតាមស្តង់ដាសកម្មភាពកម្ចាត់មីននោះ អាជ្ញាធរមីនរក្សាសិទ្ធិក្នុងការពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃអាជ្ញាប័ណ្ណទទួលស្គាល់ ដែលអាចនាំឲ្យប្រតិបត្តិករនោះបាត់បង់នូវអាជ្ញាប័ណ្ណរបស់ខ្លួន។ ជាទូទៅ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

១) បញ្ហាមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម គឺជាការទទួលខុសត្រូវថ្នាក់ជាតិពីដំបូងដល់ទីបញ្ចប់ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាមានករណីកិច្ចទទួលនូវគណនេយ្យភាព និងទទួលខុសត្រូវចំពោះជនរងគ្រោះ នៅគ្រប់តំបន់ដែលរងផលប៉ះពាល់ដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម។

២)ប្រសិនបើគ្រឿងផ្ទុះត្រូវបានរកឃើញនៅក្នុងតំបន់ដែលបានធ្វើការកាត់បន្ថយផ្ទៃដីរួច វាមិនមែនមានន័យថាប្រតិបត្តិករត្រូវទទួលខុសត្រូវដោយស្វ័យប្រវត្តិឡើយ តែត្រូវធ្វើការស៊ើបអង្កេតដោយអនុលោម

តាមស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជាជំពូក-៥ ហើយត្រូវ ឬមិនត្រូវទទួលខុសត្រូវនោះ ត្រូវមានភាពច្បាស់លាស់សិន។

៣) ជាគោលការណ៍ ប្រតិបត្តិករបោសសម្អាតមីន នឹងត្រូវទទួលខុសត្រូវក្នុងករណីគ្រោះថ្នាក់កើតឡើងដោយសារការសេសសល់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម ប្រសិនបើការស៊ើបអង្កេតបង្ហាញថា៖

ក) គ្រោះថ្នាក់កើតឡើងដោយមានចេតនា ឬដោយការប៉ុនប៉ងប្រព្រឹត្តអំពើឧក្រិដ្ឋ ការធ្វេសប្រហែសហួសហេតុ ការធ្វេសប្រហែសដោយមានគំនិតមិនល្អ រឺដោយគ្រោងទុក ដោយភាពព្រងើយកន្តើយជាក់ស្តែង ដែលនាំឲ្យមានគ្រោះថ្នាក់ដល់សិទ្ធិ ឬសុវត្ថិភាពរបស់បុគ្គលម្នាក់ ឬច្រើន។

ខ)ប្រតិបត្តិករដែលមិនមានអាជ្ញាប័ណ្ណ មិនមានលិខិតបញ្ជាក់ ឬមិនទទួលបានការអនុញ្ញាតឲ្យ ធ្វើសកម្មភាព ហើយធ្វើការសម្រេចកាត់បន្ថយផ្ទៃដីដោយការភណ្ឌ័ច្រឡំ។

គ)ប្រតិបត្តិករដែលប្រព្រឹត្តខុសនីតិវិធីធ្ងន់ធ្ងរ ឬអនុវត្តលំអៀងខ្លាំងពីស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា។

ការប្រព្រឹត្តមិនត្រឹមត្រូវតាមលក្ខខណ្ឌ ដែលបានបញ្ជាក់នៅក្នុងស្តង់ដាសកម្មភាពកម្ចាត់មីន អាចនាំទៅដល់ការព្យួរអាជ្ញាប័ណ្ណទទួលស្គាល់។ ការទទួលខុសត្រូវ និងការទាមទារសំណង ដោយសារតែនៅសេសសល់មីនមានកំហុសឆ្គងដូចបានពណ៌នាក្នុងកថាខ័ណ្ឌ១២ គ ត្រូវធ្លាក់ទៅលើប្រតិបត្តិករ ដែលពាក់ព័ន្ធ។

## ១០- ការចងក្រងឯកសារ

គោលបំណងនៃការកាត់បន្ថយផ្ទៃដីម្ការមីន គឺដើម្បីធ្វើការកែប្រែដីអោយទៅជាដីបញ្ចប់ការគម្រាមកំហែង។ ដើម្បីសម្រេចបានគោលដៅនេះ ចាំបាច់ត្រូវបំពេញឯកសារមួយចំនួនដែលខានពុំបាន។ ត្រូវបំពេញគ្រប់ឯកសារចាំបាច់ឲ្យបានត្រឹមត្រូវ មុនចាត់ផ្ទៃដីចូលជាប្រភេទដីបញ្ចប់ការគម្រាម។ ទម្រង់ឯកសារកាត់បន្ថយផ្ទៃដីក្នុងឧប សម្ព័ន្ធ-ឃ ត្រូវយកមកបំពេញ និងដាក់បញ្ចូលក្នុងឯកសារការងារឲ្យបានត្រឹមត្រូវ ចំពោះដីដែលបានលុបចោល តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ការកាត់បន្ថយតាមរយៈការស្រាវជ្រាវបច្ចេកទេស និង/ឬការកាត់បន្ថយតាម រយៈការបោសសម្អាត។ ការបំពេញទម្រង់កាត់បន្ថយផ្ទៃដី នឹងបញ្ជាក់ឲ្យឃើញថា អាជ្ញាធរដែលពាក់ព័ន្ធ និង/ឬ ប្រជាពលរដ្ឋ មានទំនុកចិត្តទៅលើដំណើរការដែលបានអនុវត្ត។ ទម្រង់កាត់បន្ថយផ្ទៃដី នឹងត្រូវប្រើសំរាប់ជាឯកសារយោង នៅពេលធ្វើការស៊ើបអង្កេត ប្រសិនបើគ្រឿងផ្ទុះត្រូវបានរកឃើញនៅក្នុងតំបន់ដែលបានកាត់បន្ថយរួច។

ត្រូវប្រើទម្រង់កាត់បន្ថយផ្ទៃដីមួយសំរាប់ពហុកោណស្រាវជ្រាវមួយ ទោះជាការងារមួយមានពហុកោណច្រើនក៏ដោយ។ ដោយមានការពិភាក្សាយ៉ាងល្អិតល្អន់ជាមួយ ក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត(MAPU) ប្រតិបត្តិករត្រូវបញ្ជាក់នូវទំហំនៃការធ្វើការងារក្នុងការដ្ឋានមួយ ដោយរួមបញ្ចូលនូវពហុកោណមួយចំនួនតាមតែអាចធ្វើទៅបាន។ យើងសង្ឃឹមថា ការងារនៅកន្លែងមួយអាចមានពហុកោណច្រើន។ មានពេលខ្លះក៏អាចគិតទុកជាមុនថា ពហុកោណដែលមានលក្ខណៈពេញលេញ អាចមិនត្រូវបានគេដាក់បញ្ចូលទៅក្នុងកិច្ចការសម្រាប់ធ្វើ ការបោសសម្អាតផងដែរ។

ក្នុងករណីបែបនេះពហុកោណ ដែលនៅសល់នោះត្រូវគិតគូរទំហំឡើងវិញ ហើយអាចលើកយកមកចាត់ចំណាត់ថ្នាក់ឡើងវិញ ដោយប្រើទម្រង់លេខ២ នៅក្នុងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជាជំពូក-១៤។ ប្រតិបត្តិករ

បោសសម្អាតមីនត្រូវសម្របសម្រួលជាមួយក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត(MAPU) នៅពេលដែលមានតម្រូវការចាំបាច់ក្នុងការបោសសម្អាតមីនលើផ្ទៃដីលើសពីកន្លះហិកតា ពីសំណើដើមរបស់ក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត(MAPU)។ នៅពេលធ្វើការកំណត់ទំហំពហុកោណជាថ្មី ផ្នែកនៃទម្រង់កាត់បន្ថយផ្ទៃដីត្រូវរក្សាទុកឲ្យបានត្រឹមត្រូវ។ ការរក្សាទុកនេះរួមមាន:

ក) ការបោសសម្អាតមានន័យថាពហុកោណដើមដែលបានមកពីការស្រាវជ្រាវទិន្នន័យមូលដ្ឋាន BLS ត្រូវបានបោសសម្អាតទាំងស្រុង នឹងត្រូវបានកែប្រែទៅជាដីប្រភេទ C ។

ខ)ការផ្អាកបណ្តោះអាសន្ន: មានន័យថាការបោសសម្អាតមីន ត្រូវបានផ្អាកមួយរយៈដោយហេតុផល ផ្សេងៗ តែក្នុងអំឡុង៣ខែ ក្រុមបោសសម្អាតមីននឹងត្រលប់មកបំពេញភារកិច្ចនេះឡើងវិញ។

គ) ការផ្អាកទាំងស្រុង: មានន័យថា ការបោសសម្អាតមីននោះ ពុំត្រូវបានបញ្ចប់ទៅតាមការស្នើឡើងរបស់ក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត(MAPU)ទេ ឬក៏ការផ្អាកបណ្តោះអាសន្នមានរយៈពេលលើសពី ៣ ខែ ដូចនេះពហុកោណដែលនៅសេសសល់ ត្រូវលើកដាក់ទៅក្នុងផែនការបោសសម្អាតមីនលើកក្រោយរបស់ក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត(MAPU)។

បើអាចកាត់បន្ថយបាន តាមរយៈ (ការបោសសម្អាត ឬការស្រាវជ្រាវបច្ចេកទេស ឬការលុបចោល) ត្រូវធ្វើទៅលើពហុកោណដែលបានស្រាវជ្រាវរួចទាំងស្រុង តែបើមិនអាចប្រតិបត្តិករត្រូវរៀបចំពហុកោណឡើងវិញដោយផ្អែកទៅលើដីដែលបានកាត់បន្ថយរួច។ នេះមិនមានន័យថា ប្រតិបត្តិករត្រូវធ្វើការស្រាវជ្រាវឡើងវិញនោះទេ ប៉ុន្តែទម្រង់លេខ២ សម្រាប់ការស្រាវជ្រាវចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជាមួយនឹងផែនទី និងទំហំចម្ការមីនថ្មីតាមការចាំបាច់ ដើម្បីញ៉ាំងឲ្យរបាយការណ៍អាចត្រូវបានរក្សាទុកដោយមានភាពសុក្រឹត្យ។



ពុំមានតំបន់សង្ស័យប្រភេទ A និង B ណាត្រូវបានផ្ទេរ-ប្រគល់ជូនសហគមន៍ដោយពុំបានបំពេញ លក្ខខណ្ឌតម្រូវដូចមានចែងក្នុងតារាងចាត់ថ្នាក់ដីប្រភេទ C នោះឡើយ។

ទម្រង់កាត់បន្ថយផ្ទៃដីចម្ការមីន ផ្តល់ឲ្យរាជរដ្ឋាភិបាលនូវភស្តុតាងថា គ្រប់កិច្ចខិតខំប្រឹងប្រែងដ៏សមហេតុផល ត្រូវបានធ្វើឡើងដើម្បីកាត់បន្ថយផ្ទៃដីចម្ការមីន។ ប្រសិនបើមិនមានការឯកភាពគ្នាលើការទទួលយកទម្រង់កាត់បន្ថយផ្ទៃដី រវាងប្រតិបត្តិករ និងសហគមន៍ដែលពាក់ព័ន្ធទេនោះ (ប្រតិបត្តិករ សហគមន៍ ឬក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត(MAPU) អាចស្នើសុំអគ្គលេខាធិការអាជ្ញាធរមីន ធ្វើជាអាជ្ញាកណ្តាល។ អគ្គលេខាធិការអាជ្ញាធរមីន នឹងធ្វើការកោះប្រជុំគណៈកម្មការដើម្បីធ្វើការដោះស្រាយ។

- ទម្រង់កាត់បន្ថយផ្ទៃដីត្រូវបានភ្ជាប់មកជាមួយទម្រង់ផ្ទេរប្រគល់បញ្ចប់ចម្ការមីនមានក្នុងឧបសម្ព័ន្ធ ជ។
- ទម្រង់កាត់បន្ថយផ្ទៃដី មិនត្រូវយកមកប្រើដើម្បីជំនួសផ្ទៃដីដែលធ្លាប់មានការគម្រាម ដូចបទបញ្ញត្តិនានាដែលមានចែងនៅក្នុងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជាជំពូក-១៤ ឡើយ។

## ១១- សកម្មភាពក្រោយការកាត់បន្ថយផ្ទៃដី

បន្ទាប់ពីផ្ទៃដីត្រូវបានកាត់បន្ថយ ការត្រួតពិនិត្យមួយនឹងត្រូវធ្វើឡើងដោយក្រុមផែនការសកម្មភាពកម្ចាត់មីនខេត្ត(MAPU) ដើម្បីតាមដាននូវការប្រើប្រាស់ដី ដែលបានកាត់បន្ថយរួច។ ប្រសិនបើរកឃើញថា ផ្ទៃដីដែលបានកាត់បន្ថយ នោះ ពុំបានប្រើប្រាស់ក្នុងអំឡុងពេល៦ខែ ទោះបីជាទម្រង់កាត់បន្ថយផ្ទៃដីបានបំពេញត្រឹមត្រូវ ហើយក៏ដោយ គឺត្រូវធ្វើការស៊ើបអង្កេតដើម្បីរកអោយឃើញប្រាកដពីមូលហេតុនៃការមិនប្រើប្រាស់។ ត្រូវអនុវត្តវិធានការណ៍សមស្រប ឆ្លើយតបទៅនឹងលទ្ធផលនៃការអង្កេតនោះ ។

## ១២- ភារកិច្ច និងការទទួលខុសត្រូវ

**អាជ្ញាធរមីនត្រូវ ៖**

ក) ជាអ្នកគ្រប់គ្រងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា ជំពូក-១៥ ដែលត្រូវថែរក្សា ធ្វើបច្ចុប្បន្នភាព និង ពិនិត្យឡើងវិញតាមការចាំបាច់។

ខ) ពិនិត្យ និងអនុម័តលើបទដ្ឋានប្រតិបត្តិការ SOP របស់ប្រតិបត្តិករបោសសម្អាតមីន ដោយធានានូវអនុលោមភាពតាមតម្រូវការនៃស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា ស្តីពីការកាត់បន្ថយផ្ទៃដីចម្ការមីន។

គ) ទទួលខុសត្រូវក្នុងការគ្រប់គ្រងគុណភាព នៃដំណើរការកាត់បន្ថយផ្ទៃដីចម្ការមីននៅប្រទេសកម្ពុជា

ឃ)ធ្វើការត្រួតពិនិត្យលើគ្រប់ទីតាំងដែលបានកាត់បន្ថយផ្ទៃដីរួច។

ង) រក្សា និងធ្វើបច្ចុប្បន្នភាពលើទិន្នន័យតាមការចាំបាច់ ដើម្បីគាំទ្រដល់ដំណើរការកាត់បន្ថយ ផ្ទៃដីចម្ការមីន។

ច) ធ្វើការស៊ើបអង្កេតកន្លែង ដែលមានការរកឃើញគ្រឿងផ្ទុះនៅក្នុងតំបន់ ដែលបានកាត់បន្ថយផ្ទៃដីចម្ការមីនរួច ។

**ប្រតិបត្តិករ ដែលពាក់ព័ន្ធការស្រាវជ្រាវ និងការបោសសម្អាតមីននៅកម្ពុជាត្រូវ ៖**

ក)បង្កើតបទដ្ឋានប្រតិបត្តិការ ឲ្យស្របទៅនឹងតម្រូវការនានានៃស្តង់ដាសកម្មភាពកម្ចាត់មីន ស្តីពីកាត់បន្ថយ

ផ្ទៃដីចម្ការមីន។

ខ)ទទួលអាជ្ញាប័ណ្ណពីអាជ្ញាធរមីន ដើម្បីធ្វើសកម្មភាពកាត់បន្ថយផ្ទៃដីចម្ការមីន។

គ) អនុវត្តតាមស្តង់ដាសកម្មភាពកម្ចាត់មីនជាតិនានា ដើម្បីអនុវត្តការកាត់បន្ថយផ្ទៃដីចម្ការមីន។

ឃ)តាមការចាំបាច់ ត្រូវផ្តល់ឯកសារប្រគល់-ទទួលផ្លូវការ នូវចម្ការមីនដែលបានវាយតម្លៃរួចឲ្យទៅ ប្រតិបត្តិករដែលធ្វើសកម្មភាពបន្ត រួមទាំងការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតកន្លែងដែលមាន ការពាក់ព័ន្ធ។

ង)ថែរក្សា និងត្រៀមជាស្រេចរាល់ឯកសារ សំរាប់ផ្តល់ជូនអាជ្ញាធរមីនបើមានការស្នើសុំ។

ច)ពិភាក្សាឲ្យបានហ្មត់ចត់ជាមួយសហគមន៍ដែលរងផលប៉ះពាល់ ពាក់ព័ន្ធទៅនឹងការសម្រេចធ្វើការកាត់បន្ថយផ្ទៃដីចម្ការមីន និងការបំពេញទម្រង់កាត់បន្ថយផ្ទៃដីចម្ការមីនស្របតាមស្តង់ដានេះ។

ឆ)រាយការណ៍នូវគ្រោះថ្នាក់ ឬឧប្បត្តិហេតុនៅក្នុងតំបន់ដែលបានកាត់បន្ថយផ្ទៃដីចម្ការមីន។

ជ)សហការជាមួយអាជ្ញាធរមីន នូវរាល់ការស៊ើបអង្កេតលើគ្រឿងផ្ទុះ ដែលបានរកឃើញនៅក្នុងតំបន់ដែលបានកាត់បន្ថយផ្ទៃដីចម្ការមីនរួច ។

ភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤

**អគ្គលេខាធិការ**

**ព្រាំ សុភមង្គល**

# ឧបសម្ព័ន្ធ ក
# បទដ្ឋានយោង

ផ្នែកខ្លះៗនៃបទដ្ឋានខាងក្រោម ត្រូវបានដកស្រង់យកមកប្រើនៅក្នុងស្តង់ដាជំពូកនេះ ៖

ក) ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា ជំពូក-០៦ តម្រូវការនានានៃការបោសសម្អាតមីន

ខ) ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា ជំពូក-០៧ តម្រូវការនានានៃការបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម

គ) ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា ជំពូក-១៤ ការស្រាវជ្រាវទិន្នន័យមូលដ្ឋាន

ឃ)ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា ជំពូក-០៥ សេចក្តីរាយការណ៍ និងការអង្កេតឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងពេលដោះមីន

ង) ស្តង់ដាសកម្មភាពកម្ចាត់មីនអន្តរជាតិ ជំពូក ០៧.១១ ការកាត់បន្ថយផ្ទៃដីចម្ការមីន

ច) ស្តង់ដាសកម្មភាពកម្ចាត់មីនអន្តរជាតិ ជំពូក ០៨.១០ ការស្រាវជ្រាវមិនបច្ចេកទេស

ឆ) ស្តង់ដាសកម្មភាពកម្ចាត់មីនអន្តរជាតិ ជំពូក ០៨.២០ ការស្រាវជ្រាវបច្ចេកទេស

ជ) អនុក្រុម៩ នៃស្តង់ដាសកម្មភាពកម្ចាត់មីនអន្តរជាតិ ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម

កំណែ/ការបោះពុម្ព ចុងក្រោយបង្អស់ នៃឯកសារយោងទាំងនេះ ត្រូវបានយកមកប្រើ ។

Annex B: Land Release Process




**សំគាល់:** ប្រសិនបើក្នុងពេលប្រើសំការៈសំរាប់ដោះមីនតាមវិធីបោសសំអាតមីនទាំងស្រុងមិនអាចរកឃើញមីន ត្រូវធ្វើការពិនិត្យឡើងវិញនូវវិធីសាស្រ្ត ដែលបានប្រើ ហើយត្រូវធ្វើការស្រាវជ្រាវបច្ចេកទេសទៅលើពហុកោណនោះបន្ថែមទៀត ដើម្បីកំណត់តំបន់គ្រោះថ្នាក់ ឬធ្វើការកាត់បន្ថយផ្ទៃដីតំបន់នោះតាមលក្ខណៈសមស្រប។ ជាគោលការណ៍ ចំណុចដែលចាត់ទុកថាអស់គ្រោះថ្នាក់គឺ ២៥ម៉ែត្រ ពីគ្រាប់មីនចុងក្រោយដែលបានរកឃើញ។

**ឧបសម្ព័ន្ធ គ**

## ស្តង់ដាចាត់ថ្នាក់ប្រភេទដី

| ចំណាត់ថ្នាក់ | ចំណាត់ថ្នាក់បន្ទាប់ | | សេចក្តីលម្អិត អំពីចំណាត់ថ្នាក់បន្ទាប់ | កំណត់សម្គាល់ |
|---|---|---|---|---|
| **A** **តំបន់មានមីន** ដីមានភស្តុតាងថាមានមីន | **A1** | ដីមានដង់ស៊ីតេមីនប្រឆាំងមនុស្សច្រើន | ដីមានដាក់មីន ជាលក្ខណៈយុទ្ធសាស្ត្រ ដាក់ការពារដោយមានទ្រង់ទ្រាយច្បាស់លាស់ ដូចជាខ្សែក្រវ៉ាត់មីន តាមបណ្តោយផ្លូវ តាមព្រំដែន តាមមូលដ្ឋានទ័ព និង តាមហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | ការពង្រាយកំលាំងបោសសំអាតមីន មនុស្សធម៌ គួរផ្តោត លើដី **A1-A3** ដើម្បីឆ្លើយតបនឹង អាទិភាពរបស់សហគមន៍ ។ គ្រប់ពហុកោណគួរ ធ្វើការអង្កេតបន្ថែមដើម្បីបាន ដឹងបរិវេណដី មានមីន មុនពេលពង្រាយកំលាំង ដោះមីន ។ ការពង្រាយកំលាំង ដោះមីនលើដី **A4** គួរគិត ចំពោះដី ដែលមានការកំណត់ជាក់លាក់ សំរាប់ កិច្ចអភិវឌ្ឍន៍ |
| | **A2.1** | ដីមានដង់ស៊ីតេមីនប្រឆាំងមនុស្ស និងមីន ប្រឆាំងរថក្រោះ ដាក់លាយចំរុះគ្នាច្រើន | | |
| | **A2.2** | ដីមានមីនប្រឆាំងមនុស្ស និងមីនប្រឆាំង រថក្រោះ នៅរាយប៉ាយ | ដីមិនបានប្រើប្រាស់បង្ករបង្កើនផល ដោយមានមីនប្រឆាំងមនុស្ស និងមីន ប្រឆាំងរថក្រោះតិចតួច ហើយយើងមិនអាចកំណត់ទីកន្លែងដាក់មីនបាន | |
| | **A3** | ដីមានមីនប្រឆាំងរថក្រោះ | ដងផ្លូវកំពុងប្រើប្រាស់ ឬ បោះបង់ចោល ដែលមានមីនប្រឆាំងរថក្រោះ | |
| | **A4** | ដីមានមីនប្រឆាំងមនុស្ស នៅរាយប៉ាយ ដែលមិនអាចកំណត់ ទីតាំងមីនបាន | ដីមិនបានប្រើប្រាស់បង្ករបង្កើនផល ដោយមានមីនប្រឆាំងមនុស្សតិចតួច ហើយយើងមិនអាចកំណត់ ទីកន្លែងដាក់មីនបាន | |
| **B** (**ដីនៅសល់ការគំរាម កំហែងតិចតួច**) ដីមានភស្តុតាងបញ្ជាក់ថា មាន គ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម ឬមិនអាចកំណត់បានថាមានមីន | **B1** | ដីមានគ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) (តែពុំមានមីន) | តំបន់អតីតសមរភូមិដែលមាន គ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម ។ តំបន់ប្រភេទនេះមាន លក្ខណៈសមស្របសំរាប់ការបោសសំអាតគ្រាប់ (Battle Area Clearance) | តំបន់អតីតសមរភូមិដែលមានគ្រាប់ សំណល់ ជាតិផ្ទុះពីសង្គ្រាម ។ តំបន់ប្រភេទនេះមាន លក្ខណៈសមស្រប សំរាប់ការបោសសំអាតគ្រាប់ (Battle Area Clearance) ការពង្រាយកំលាំងបោសសំអាតមីន លើដីប្រភេទ **B** ធ្វើតែចំពោះដីដែល ឆ្លើយតបទៅនឹង តម្រូវការរបស់សហគមន៍ប៉ុណ្ណោះ |
| | **B1.1** | ដីមានគ្រាប់ទំលាក់ពីយន្តហោះ | មានទិន្នន័យគ្រាប់ដែលបានទំលាក់ ឬមានភស្តុតាងគ្រាប់ទំលាក់ពីយន្តហោះ | |
| | **B1.2** | ដីមានគ្រាប់ចង្កោម | មានទិន្នន័យពីការទំលាក់គ្រាប់ ឬមានភស្តុតាងថាតំបន់មួយមានគ្រាប់ចង្កោម | |
| | **B1.3** | តំបន់ទីតាំងសមរភូមិ | តំបន់ទាំងឡាយដែលមានភស្តុតាងបញ្ជាក់ថាធ្លាប់មានការប្រយុទ្ធ | |
| | **B1.4** | ដីដែលមានគំនរគ្រាប់/គ្រាប់កប់ | តំបន់ទាំងឡាយដែលនៅមានគ្រាប់កប់ ឬមានគំនរគ្រាប់ | |
| | **B1.5** | ទីតាំងយោធាដែលបានបោះបង់ | តំបន់ទាំងឡាយដែលអាចមានការសង្ស័យក៏រិតខ្ពស់ថាមានគ្រាប់រំសេវ | |
| | **B2** | ដីមិនអាចកំណត់បានថា មាន ការគំរាមកំហែងដោយសារមីន | ដីធ្លាប់សង្ស័យថាមានមីន តែត្រូវបានប្រជាពលរដ្ឋទន្ទ្រានយកមកប្រើប្រាស់ ។ ប្រសិនបើពុំមាន គ្រោះថ្នាក់ ឬ ពុំជួបប្រទះឃើញមីនរយៈពេល ៣ឆ្នាំ ដីប្រភេទនេះត្រូវចាត់ថ្នាក់ ជាដីប្រភេទ **C1** | |
| **C** (**ដីបញ្ចប់ការគំរាម កំហែង**) ដីពុំមានភស្តុតាងបញ្ជាក់ថា មានការគំរាមកំហែង | **C1** | ដីលប់ចោលការសង្ស័យ / ដីទន្ទ្រានយកមកប្រើប្រាស់ | ដីធ្លាប់សង្ស័យថាមានមីនតែត្រូវបានប្រជាពលរដ្ឋទន្ទ្រានយកមកប្រើប្រាស់ដោយពុំមានគ្រោះ ថ្នាក់ ឬពុំមានប្រទះឃើញមីនរយៈពេល៣ឆ្នាំ ដូចមានចែងក្នុងនយោបាយកាត់បន្ថយផ្ទៃដីចំការមីន | មិនគួរពង្រាយកំលាំងបោសសំអាតមីនមនុស្សធម៌ លើដីប្រភេទនេះទេ |
| | **C2** | ដីត្រូវបានកាត់បន្ថយដោយការស្រាវជ្រាវ បច្ចេកទេស | ដីមានមីន ឬ ធ្លាប់សង្ស័យថាមានមីនតែត្រូវបានឆែកមើលតាមវិធីស្រាវជ្រាវណាមួយ ដែលបញ្ជាក់ថា ពុំមានភស្តុតាង ថានៅមានសេសសល់ការគំរាមកំហែងទៀត | |
| | **C3** | ដីបានបោសសំអាតមីនរួច | ដីបានបោសសំអាតមីនរួច ដោយប្រតិបត្តិករដែលទទួលបានអាជ្ញាប័ណ្ណ ពីអាជ្ញាធរមីន ហើយបាន អនុវត្តន៍តាមស្តង់ដាជាតិបោសសំអាតមីន (CMAS) | |

 Annex D:

អាជ្ញាធរមីន
C.M.A.A

# ទម្រង់របាយការណ៍កាត់បន្ថយផ្ទៃដីចម្ការមីន/គ្រាប់

## Land Release Report Form

| |
|---|
| កូដ/ Land Release Code: **LR/CMAA/** |
| ប្រតិបត្តិករ/ Organization: |
| ការិយាល័យ/ Regional Office: |
| លេខកូដប្រតិបត្តិករ / Operator code (optional): |
| កាលបរិច្ឆេតបញ្ចប់ចម្ការមីន/ Date of Completion Task: |

| 1. ទីតាំងកាត់បន្ថយផ្ទៃដី/Task Location | | | |
|---|---|---|---|
| លេខកូដភូមិ/ Village Code: | | | |
| ភូមិ/ Village: | ☐ ថ្មី | ឃុំ/ Commune: | ☐ ថ្មី |
| ស្រុក/ District: | ☐ ថ្មី | ខេត្ត/ Province: | ☐ ថ្មី |

| 2. ព័ត៌មានការងារ/ Tasking Information | | | |
|---|---|---|---|
| លេខកូដស្រាវជ្រាវ/ BLS Code | BS/CMAA/.......................... | ការចាត់ថ្នាក់ប្រភេទដី Land Classification: | ☐ A1 ☐ A2 ☐ A2.1 ☐ A2.2 ☐ A3 ☐ A4<br>☐ B1 ☐ B1.1 ☐ B1.2 ☐ B1. ☐ B1.4 ☐ B1.5<br>☐ B2 |
| តើការងារនេះមាននៅក្នុងផែនការម៉ាពូដែរឬទេ?/ Is the task recorded in MAPU work plan? | | ☐ No<br>☐ Yes ប្រសិនបើមាន សូមផ្តល់លេខកូដ/ If YES, provide task ID:………………... | |
| កាលបរិច្ឆេទអនុម័តចម្ការមីន ដោយភីម៉ាក/ PMAC Approved Date: ថ្ងៃខែឆ្នាំ/ Date: / / | | | |
| ចំនួនផ្ទៃដីដែលស្នើសុំកាត់បន្ថយ/ Area requested to release: ម៉ែត្រការ៉េ ($m^2$) | | | |
| ប្រសិនបើការងារមិនស្ថិតនៅក្នុងផែនការរបស់ ម៉ាពូ សូមផ្តល់ហេតុផលដែលត្រូវធ្វើការក្នុងការដ្ឋាននេះ /If the task is not in MAPU work plan, provide reason for working on site: | | | |

| 3. វិធីសាស្ត្រដែលប្រើសំរាប់កាត់បន្ថយផ្ទៃដី/ Method Used To Release Land | |
|---|---|
| ☐ ដោយការស្រាវជ្រាវមិនបច្ចេកទេស/ Non-technical Survey (C1) | ប្រសិនគូសប្រអប់នេះសូមបំពេញចំនុចលេខ ៤ (if this box is ticked, go to section 4) |
| ☐ ដោយការស្រាវជ្រាវបច្ចេកទេស/ Technical Survey (C2) | ប្រសិនគូសប្រអប់នេះសូមបំពេញចំនុចលេខ ៥ (if this box is ticked, go to section 5) |
| ☐ ដោយការបោសសម្អាត/ Clearance (C3) | ប្រសិនគូសប្រអប់នេះសូមបំពេញចំនុចលេខ ៦ (if this box is ticked, go to section 6) |

| 4. ការកាត់បន្ថយដោយការស្រាវជ្រាវមិនបច្ចេកទេស/ Land Release through Non-technical Survey (C1) | | | |
|---|---|---|---|
| វិធីសាស្ត្រប្រើដើម្បីភ្ជួរដី/ Method used to till the land: | ☐ គោ/ Cows | ☐ គោយន្ត/ Rotivator | ☐ ត្រាក់ទ័រ/ Tractor |
| ថ្ងៃចាប់ផ្តើម/ Started date: | ថ្ងៃបញ្ចប់ (Ended date):´´´ | | |
| ចំនួនថ្ងៃធ្វើការ/ Number of working days: | លេខសំគាល់ក្រុម/ Team ID: | | |
| ដីត្រូវបានដាក់អោយប្រើប្រាស់ក្នុង/ Land was put into productive use in | ថ្ងៃ/Day: | ខែ/Month: | ឆ្នាំ/Year: |
| ចំនួននៃការភ្ជួរាស់/ Number of times ploughed: | ដង/Time: | | |
| វត្ថុមានមីនចុងក្រោយដែលបានរកឃើញ/ Latest evidence of mine on land | ថ្ងៃ/Day: | ខែ/Month: | ឆ្នាំ/Year: |
| គ្រោះថ្នាក់មីនចុងក្រោយ/ Latest mine accident on land | ថ្ងៃ/Day: | ខែ/Month: | ឆ្នាំ/Year: |
| ពន្យល់ហេតុផលក្នុងការលុបចោលតំបន់សង្ស័យនិងការទន្ទ្រាន/ Detail reasons for cancellation or reclamation: | | | |

| | |
|---|---|
| | |
| ទំហំផ្ទៃដីដែលបានកាត់បន្ថយតាមការលុបចោល/ GIS Area cancelled: m$^2$ | សារុប: m$^2$ |
| ទំហំផ្ទៃដីដែលបានកាត់បន្ថយតាមការទន្រ្ទាន /GIS Area reclaimed: m$^2$ | |
| តើអ្នកណាជាម្ចាស់ជំនួយសំរាប់ប្រតិបត្តិការនេះ?/ Who is the donor supporting this operation?: | |
| **ចំណាំ**: (C1) គោលការណ៍លុបចោលតំបន់សង្ស័យមានមីនបានចែងលម្អិតក្នុង CMAS 15 ឧបសម្ព័ន្ធ F (C1) a Cancellation criteria are detailed in CMAS 15 Annex F | |

| **5.** ការកាត់បន្ថយផ្ទៃដីតាមការស្រាវជ្រាវបច្ចេកទេស / Land Released Through Technical Survey (C2) | | |
|---|---|---|
| ឧបករណ៍ប្រើប្រាស់ | ☐ ដោយដៃ (Manual) ☐ សត្វ (EDA): ☐ គ្រឿងចក្រ (Mechanical): ☐ ផ្សេងៗ (Other): | |
| ថ្ងៃចាប់ផ្តើម/ Started date: | | ថ្ងៃបញ្ចប់ (Ended date): |
| ចំនួនថ្ងៃធ្វើការ/ Number of working days: | | លេខសម្គាល់ក្រុម/ Team ID: |
| ទំហំផ្ទៃដីដែលបានកាត់បន្ថយ/ Area Released | ការស្រាវជ្រាវតាមប្រព័ន្ធ/ Systematic Investigation (SI): m$^2$ | |
| | ផ្ទៃដីបោសសំអាតពុះប្រអប់/Breaching lane: m$^2$ | |
| | ផ្ទៃប្រអប់បោសសំអាត/ Investigated Box: m$^2$ | |
| | ប្រអប់មិនត្រួតពិនិត្ត/Uninvestigated Box m$^2$ | |
| | ការស្រាវជ្រាវតាមគោលដៅ/ Targeted Investigation (TI): m$^2$ | |
| | ផ្ទៃដីពិនិត្យគោលដៅ/ Targeted Investigated Area: m$^2$ | |
| | ផ្ទៃដីមិនតម្រូវការពិនិត្យ Uninvestigated Area: m$^2$ | |
| | ការស្រាវជ្រាវទាំងស្រុង/ Full Coverage Investigation (FCI): m$^2$ | |
| | ផ្ទៃដីសរុប/Total area released: m$^2$ (=area SI+TI+FCI ) | |
| | ផ្ទៃដីសរុបតាមGIS Calculation: m$^2$ | |
| តើមានតំបន់រដ្ឋបាលដែលបានបោសសម្អាតស្ថិតនៅក្រៅ BLS ដែរឬទេ? (Is there administrative area cleared outside of BLS?) | | ☐ NO ☐ YES, If yes/ប្រសិនបើមាន:.............................m$^2$ |
| តើមានការកាត់បន្ថយផ្ទៃដីបន្ថែម នៅក្រៅ BLS ដែរឬទេ?/ Is there any extra technical survey outside the BLS area? ☐ NO ☐ YES: if yes, ប្រសិនបើមាន ទំហំផ្ទៃដី/ Area size: .................... ................................(m$^2$) សូមបញ្ជាក់ពីហេតុផល/ Please provide reasons:....................... ...................................................................... ........................................................................................................................................... | | |
| តើអ្នកណាជាម្ចាស់ជំនួយសំរាប់ប្រតិបត្តិការនេះ ?/ Who is the donor supporting this operation?: | | |

| **6.** ការកាត់បន្ថយដោយការបោសសម្អាត/ Land Release Through Clearance (C3) | | |
|---|---|---|
| ឧបករណ៍ប្រើប្រាស់: ☐ ដោយដៃ (Manual) ☐ សត្វ (EDA): ☐ គ្រឿងចក្រ (Mechanical): ☐ ផ្សេងៗ (Other): | | |
| ថ្ងៃចាប់ផ្តើម/ Started date: | | ថ្ងៃបញ្ចប់ /Finished date: |
| ចំនួនថ្ងៃធ្វើការ/ Number of working days: | | លេខសម្គាល់ក្រុម (Team ID) : |
| ទំហំផ្ទៃដីដែលបានបោសសម្អាត /Area cleared | តាមផ្ទៃដីប្រតិបត្តិការ/ Operational: m$^2$ | |
| | តាមផ្ទៃដី/ GIS Calculation: m$^2$ | |
| ជម្រៅដែលទាមទារឲ្យធ្វើការបោសសម្អាត /Required clearance depth: cm | | |
